# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៦.......សរ.ដក

## សារជូនពរ

របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
និង ជាប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងឱកាស
ខួបលើកទី ៥៥ ទិវាកុមារអន្តរជាតិ ១ មិថុនា និង ទិវា
ពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ឆ្នាំ ២០០៤

~~~~~~~~~

-សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ !

-ជនរួមជាតិជាទីស្នេហា !

-ក្មួយៗកុមារា កុមារីជាទីស្រលាញ់ !

នៅក្នុងឱកាសដ៏មហោឡារិកនៃខួបលើកទី៥៥ **ទិវាកុមារអន្តរជាតិ ១ មិថុនា និង ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ឆ្នាំ២០០៤** នេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និង ក្នុងនាមខ្លួនខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមសម្តែងនូវក្តីរីករាយជាអតិបរិមាចំពោះ ការប្រារព្ធទិវាដ៏មានសារៈសំខាន់នេះរបស់ក្មួយៗកុមារទាំងអស់ ហើយសូមឱ្យការប្រារព្ធពិធីនេះនៅគ្រប់ទីកន្លែងប្រព្រឹត្តិទៅប្រកបដោយជោគជ័យ ។

ខ្ញុំសូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹង ចំពោះសកម្មភាពទាំងឡាយដែលបាន និង កំពុងអនុវត្ត ក្នុងទិសដៅឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងជាមូលដ្ឋានទាំងឡាយរបស់កុមារ ដូចដែលបានចែងក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ សំរាប់កុមារកម្ពុជា និង កុមារគ្រប់សញ្ជាតិ គ្រប់ពណ៌សម្បុរ ដែលកំពុងមានវត្តមាននៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ។

រាជរដ្ឋាភិបាល និង ពលរដ្ឋកម្ពុជាគ្រប់រូប មានកាតព្វកិច្ចធ្វើអោយសុខុមាលភាពរបស់កុមារកាន់តែប្រសើរឡើង ដោយអោយកុមារអាចរស់នៅតាមបញ្ញតិធម្មជាតិ ប្រកបដោយការរីកចំរើនធំធាត់ជាមនុស្សពេញវ័យ មានសុខភាពល្អ បញ្ញាស្មារតីវាងវៃ មានចំណេះដឹងខ្ពង់ខ្ពស់ រស់នៅក្នុងសន្តិភាព និង ភាពថ្លៃថ្នូរ ។ ការអភិវឌ្ឍន៍កុមារ និង ការកាត់បន្ថយភាពក្រីក្រ ជាគន្លឹះដ៏មានសារៈសំខាន់បំផុតដើម្បីផ្តល់ឱកាសអោយកុមារ ក្រេបយកចំណេះដឹងទូទៅ បច្ចេកទេសជំនាញទាំងឡាយ ឈានទៅទទួលនូវសិទ្ធិអំណាចខាងផ្នែកសេដ្ឋកិច្ច សង្គម ព្រមទាំងជួយអោយក្មួយៗអាចប្រើប្រាស់
~~~~~~~~~

បានពេញលេញនូវសមត្ថភាពរបស់ខ្លួន ដើម្បីចូលរួមវិភាគទានជាវិជ្ជមាន ក្នុងការអភិវឌ្ឍប្រទេសជាតិលើ គ្រប់វិស័យ ហើយនាំសង្គមជាតិឈានទៅរកវឌ្ឍនភាពដ៏សម្បូររុងរឿង ស្របទៅនឹងសង្វាក់ភិពពលោកនាពេលអនាគត ។

ដើម្បីសំរេចបាននូវគោលដៅដ៏ឧត្តុង្គឧត្តមនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តអនុវត្តអោយបានល្អប្រសើរ នូវគោលនយោបាយ ផែនការ និង យុទ្ធសាស្ត្រជាតិ ដោយផ្តោតជាពិសេសលើបញ្ហា៤ជាអាទិភាពគឺ :

- **ការកាត់បន្ថយអត្រាមរណភាពរបស់មាតា និង ទារក** ដោយបង្កើនសេវាថែទាំសុខភាពមាតា និង ទារក
- **ការអប់រំប្រកបដោយគុណភាព និង ការកាត់បន្ថយគម្លាតយេនឌ័រ**
- **ការប្រយុទ្ធនឹងមេរោគអេដស៍ / ជម្ងឺអេដស៍**
- **កិច្ចការពារកុមារ ប្រឆាំងការជួញដូរ ការកេងប្រវ័ញ្ច និង ការរំលោភបំពាន** ពិសេសការរំលោភផ្លូវភេទលើកុមារ ដែលជាការរំលោភសិទ្ធិដ៏ធ្ងន់ធ្ងរ ។

ក្នុងឱកាសដ៏ល្អប្រពៃនេះ ខ្ញុំព្រះករុណាខ្ញុំសូមឧទ្ទិសអោយទិវា ១ មិថុនា និង ១២ មិថុនា ក្លាយទៅជាការប្តេជ្ញាចិត្តជាសកល និង ទៅជាការអំពាវនាវរបស់កុមារដល់គ្រប់ស្ថាប័នជាតិ សហគមន៍ និង ពលរដ្ឋកម្ពុជាគ្រប់រូប សូមផ្តល់ការយកចិត្តទុកដាក់ខ្ពស់ដល់កុមារ ដែលជាសសរទ្រូងរបស់ប្រទេសជាតិ ។

ខ្ញុំព្រះករុណាខ្ញុំ សូមសំដែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្រ និង ការវាយតម្លៃខ្ពស់បំផុត ចំពោះទឹកចិត្តស្រលាញ់ ចិញ្ចឹមបីបាច់ថែរក្សា ព្យាបាល អប់រំ បណ្តុះបណ្តាល និង ធ្វើពលិកម្មគ្រប់បែបយ៉ាងដែលប្រកបដោយ ព្រហ្មវិហារធម៌ដ៏ថ្លៃថ្លា របស់មាតាបិតាចំពោះបុត្រធីតា លោកគ្រូអ្នកគ្រូចំពោះសិស្សានុសិស្ស និងសូមកោតសរសើរ ដល់ស្មារតីយកចិត្តទុកដាក់ និង ទទួលខុសត្រូវរបស់មន្ត្រីរាជការ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាល ដែលបានបំ ពេញភារកិច្ចលើកស្ទួយដល់សិទ្ធិកុមារ ។ ទន្ទឹមនេះដែរ ខ្ញុំសូមឱ្យក្មួយៗខិតខំប្រឹងប្រែងរៀនសូត្រ និង ថែរក្សាប្រពៃណីខ្មែរ ដើម្បីក្លាយខ្លួនទៅជាកូនល្អ សិស្សល្អ មិត្តល្អ និង ជាពលរដ្ឋល្អក្នុងថ្ងៃអនាគត ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរដល់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និង ជូនពរចំពោះជនរួមជាតិជាទីស្នេហា ក្មួយៗទាំងអស់ សូមប្រកបដោយសេចក្តីសុខគ្រប់ប្រការ និង មានសិរីសួស្តីដ៏ត្រចះត្រចង់ មានជោគជ័យលើរាល់ភារកិច្ច ជំនះរាល់ការលំបាកដើម្បីបុព្វហេតុជាតិមាតុភូមិ និង បុព្វហេតុរួមរបស់កុមារកម្ពុជា ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ[illegible] ឆ្នាំ២០០៤*

**ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា